# សេចក្តីសន្និដ្ឋាន

អំពើពុករលួយក្នុងវិស័យឯកជនមានលក្ខណៈស្មុគ្រស្មាញ។ ទាំងសហគ្រាស និងទាំងមន្ត្រីសាធារណៈសុទ្ធតែបានពាក់ព័ន្ធនឹងអំពើពុករលួយ ដែលមានពាសពេញផ្ទៃប្រទេសដោយសារតែប្រព័ន្ធនៃភាពជាចៅហ្វាយនេះ និងបក្សពួក។

មន្ត្រីសាធារណៈ ដែលត្រូវធ្វើការជាមួយវិស័យឯកជន ជាញឹកញាប់ចុះទស្សនកិច្ចទីតាំងសហគ្រាស ក្រោមរូបភាពអធិការកិច្ចក្នុងគោលបំណងដើម្បីទារសំណូក។ ជាទូទៅ មន្ត្រីទាំងនេះរួមមាន: ភ្នាក់ងារពន្ធដារ ប៉ូលីស អាជ្ញាធរមូលដ្ឋាន មន្ត្រីសុវត្ថិភាពអគ្គីភ័យនិងអាគារ មន្ត្រីបរិស្ថាន។ល។ ការិយាធិបតេយ្យស្មុគ្រស្មាញ និងកង្វះតម្លាភាពក្នុងបទបញ្ញត្តិ និងច្បាប់នានា ជាមូលហេតុមួយយ៉ាងសំខាន់នៃការរីករាលដាលអំពើពុករលួយ។

ទោះបីជា ទំហំនៃអំពើពុករលួយក្នុងវិស័យឯកជនហាក់បីដូចជាធ្លាក់ចុះ បើធៀបនឹងការវាយតម្លៃរបស់ធនាគារពិភពលោកក្នុងឆ្នាំ ២០០៤ ក៏ដោយ ក៏ទំហំនេះនៅតែខ្ពស់នៅឡើយ។ ដើម្បីទប់ស្កាត់អំពើពុករលួយ បញ្ហាឫសគល់ដែលនាំអោយមានអំពើពុករលួយទាំងនេះ គួរត្រូវតែដោះស្រាយ។ មូលហេតុចំបង៧នៃអំពើពុករលួយនៅក្នុងវិស័យឯកជននេះរួមមាន: "ប្រាក់ខែទាបរបស់មន្ត្រីរាជការ" "កង្វះយន្តការប្រឆាំងនឹងអំពើពុករលួយ" "វប្បធម៌នៃអំពើពុករលួយ" "កង្វះឯករាជ្យភាពតុលាការនិងប្រសិទ្ធភាព" និង "ការអនុវត្តច្បាប់ខ្សោយ"។

ប្រសិនជាអំពើពុករលួយក្នុងវិស័យឯកជនត្រូវបានលុបបំបាត់ចំនួនប្រាក់ ដែលបាត់ដោយសារអំពើពុករលួយនេះ អាចយកមកប្រើឱ្យកាន់តែមានប្រសិទ្ធភាពជាងនេះទៅទៀតក្នុងការអភិវឌ្ឍ។ បរិមាណនៃការបាត់បង់នេះ (៣៣០ លានដុល្លារ ក្នុងឆ្នាំ ២០០៥) មានចំនួនលើសពីសេចក្តីត្រូវការចាំបាច់សម្រាប់យកទៅតម្លើងបៀវត្សរ៍មន្ត្រីរាជការដល់កម្រិត ជាមធ្យម ១០០ ដុល្លារអាមេរិក ក្នុងមួយខែ។ អំពើពុករលួយត្រូវកាត់បន្ថយ ឯសេវាសាធារណៈក៏កាន់តែមានប្រសិទ្ធភាព។

ជាងនេះទៅទៀត ដោយសារប្រព័ន្ធអំពើពុករលួយ រដ្ឋាភិបាលអាចប្រមូលពន្ធបានតែប្រហែល ២៥ ភាគរយ នៃចំណូលពន្ធសក្តានុពលសរុបប៉ុណ្ណោះ។ ការខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការប្រមូលចំណូលរដ្ឋឱ្យបានកាន់តែច្រើន គួរផ្តោតលើការធ្វើឱ្យប្រព័ន្ធពន្ធដារមានលក្ខណៈសាមញ្ញ និងប្រកបដោយតម្លាភាពក្នុងការប្រមូលពន្ធ។ ប្រព័ន្ធមានលក្ខណៈសាមញ្ញ និងប្រកបដោយតម្លាភាព ធ្វើឱ្យសហគ្រាសឯកជនងាយយល់ និងជៀសវាងការបង់សំណូក។ ជាមួយគ្នានេះផងដែរ រដ្ឋាភិបាលគួរពិចារណាឡើងវិញពីអត្រាពន្ធដែលត្រូវបង់ដោយ មីក្រូសហគ្រាស និងសហគ្រាសធុនតូច និងមធ្យម ដើម្បីលើកទឹកចិត្តពួកគាត់ក្នុងការបង់ពន្ធ។